# ឧទាហរណ៍ក្នុងការអនុវត្តកសិកម្មលាយផ្សំក្នុងកសិដ្ឋានគ្រួសារ

បើកសិករដាំដំណាំតែមួយមុខ កសិករនឹងចាំបាច់ពឹងលើអ្នកដទៃដើម្បីរស់ ព្រោះបើដាំតែស្រូវ ឬធ្វើតែចម្ការស្វាយតែមួយមុខ កសិករនឹងត្រូវយកប្រាក់ដែលបានពីដាំស្រូវ ឬស្វាយនោះទៅទិញរបស់ដែលជាអាហារពីអ្នកដទៃ តែបើកសិករដាំដំណាំចម្រុះច្រើនមុខ និងចិញ្ចឹមបសុសត្វគ្រប់ប្រភេទ កសិករនឹងមិនចាំបាច់ពឹងច្រមុះអ្នកដទៃដើម្បីរស់ឡើយ។

កសិករថៃមួយរូបដែលជាម្ចាស់ចម្ការទុរេននៅខេត្តឈុមផន មាត់ទ្វារភូមិភាគទក្សិណនៃប្រទេសថៃ បានធ្លាក់ខ្លួនក្រជំពាក់ប្រាក់គេឯងវណ្ឌែកព្រោះតែចង់មានចង់បានឆាប់រហ័សពេក។

លោក សុំប៊ូន ស៊ីស៊ុបាត់ នៅភូមិថៈណម ឃុំឆង់ម៉ៃកែវ ស្រុកធុងតាកូ គឺជាកសិករដែលពីដើមដាំដំណាំតែមួយមុខ គឺទុរេនពូជម៉នថង។ ទឹកចិត្តគាត់គិតតែថាធ្វើយ៉ាងណាឲ្យឆាប់មានឆាប់បាន ៖ *"មុននេះខ្ញុំគិតតែពីខាងពាណិជ្ជកម្មពីខាងធុរកិច្ច ធ្វើម៉េចឲ្យឆាប់មាន ធ្វើយ៉ាងណាឲ្យបានច្រើន គឺបន្ទាន់ចង់មានឆាប់ៗ"*។

សួរថាតើគាត់បានចំណាយប្រាក់អស់ទៅលើអ្វីខ្លះ? លោក សុំប៊ូន ដែលក្រោយពីក្ស័យធន រហូតដល់គិតចង់ធ្វើអត្តឃាតសម្លាប់ខ្លួនឯង ប្រាប់ថា ៖ *"ថ្លៃជី ថ្លៃសាំង ថ្លៃពលកម្ម ថ្នាំអ័រម៉ូន ហើយនិងថ្នាំសម្លាប់សត្វល្អិតបាញ់រាល់អាទិត្យ។ គេថាឲ្យដាក់ជីច្រើន ខ្ញុំក៏ដាក់ច្រើន ប្រើជីប្រភេទដាក់ការុងលើស្មា បើកមាត់ការុងហើយដើរចាក់ពង្រាយតាមគល់ទាល់តែសក្បុស"*។

បន្ទាប់ពីចំណាយកម្លាំងកាយនិងកម្លាំងទ្រព្យទៅលើចម្ការទុរេនទំហំជាង ១៧រ៉ៃ ឬស្មើនឹងជាង ២ហិកតារ កន្លះនោះមក លោក សុំប៊ូន ក៏ក្លាយទៅជាមនុស្សមានបំណុលរុំកោះ ជំពាក់ប្រាក់មិត្តភក្តិនិងម្ចាស់ហាងជីនិងថ្នាំគីមី ជិតមួយលានបាត។ ដោយអស់កម្លាំងកាយនិងកម្លាំងចិត្ត ព្រមទាំងកម្លាំងទ្រព្យខ្លាំងពេក លោក សុំប៊ូន បានមៅចម្ការឲ្យឈ្មួញទុរេន ហើយពួកគេក៏បានប្រើវិធីគាបដើមទុរេនឲ្យចេញផ្លែខុសរដូវ។ ក្នុងការបង្ខំទុរេនឲ្យចេញផ្លែក្រៅរដូវនេះ គេត្រូវប្រើសារធាតុគីមីបាញ់បញ្ចូលទៅក្នុងគល់ដើមទុរេន និងយកសារធាតុគីមីស្រោចគល់យ៉ាងជោកជាំ។

លោក សុំប៊ូន អធិប្បាយថា ៖ *"ការធ្វើឲ្យទុរេនចេញផ្លែខុសរដូវ គឺការគាបបង្ខំឲ្យទុរេនជិតស្លាប់។ ដំបូងគេបំប៉នវាឲ្យស្លឹកនិងដើមមានអាហារគ្រប់គ្រាន់ ស្លឹកឡើងស្រស់បំព្រង រួចហើយគេបញ្ឈប់ការរីកលូតលាស់របស់វា បង្អត់អាហារវា គាបឲ្យវាចេញផ្លែ។ បញ្ហានៅត្រង់យើងមិនដឹងថា តើត្រូវធ្វើយ៉ាងណាទើបអាចជួយដាស់ដើមទុរេនធ្វើឲ្យវាមានកម្លាំង ឲ្យវាលូតលាស់ឡើងវិញ ព្រោះថា ក្រោយអស់កិច្ចសន្យាហើយពួកឈ្មួញគេនាំគ្នាទៅបាត់អស់។ ខ្ញុំដើរមើលដើមទុរេន ឃើញស្លឹកវាឡើងលឿង។ ពេលខ្យល់បក់ម្តងៗ ស្លឹកវាជ្រុះស្រោចមកលើដី។ ដើមទុរេនស្ទើរងាប់អស់ពីចម្ការ។ ពេលខ្ញុំទៅសួរគោម*

*ហាងលក់ថ្នាំគីមីទាំងនោះ ពួកនៅហាងក៏ចង់លក់ថ្នាំរបស់គេ។ ដូច្នេះគេណែនាំថាឲ្យប្រើថ្នាំនេះល្អ ឬថ្នាំនោះល្អ ដល់យើងទៅដល់គេក៏ត្រៀមថ្នាំឲ្យ តែតម្លៃវាថ្លៃទាល់តែមែនទែន ម្តងៗ ៤-៥ម៉ឺនបាត យកមកបាញ់ម្តង-ពីរដង ក៏អស់ចាំបាច់ត្រូវតែទៅរកទៀត ហើយត្រូវចំណាយ ៥-៦ម៉ឺនទៀត។ ដំបូងនៅមានលុយមិនអីទេ តែក្រោយមកគ្មានលុយក៏ចាំបាច់ត្រូវជំពាក់គេសិន។ ទិញជឿគេរហូតដល់ជំពាក់បំណុលនៅគ្រប់ហាង ទាល់តែគេលែងឲ្យស៊ីញ៉េជឿ"*។

លោក ស៊ុំប៊ូន អស់សង្ឃឹមខ្លាំង ទាំងក្បែយទុនផង បាត់អស់កិត្តិយសព្រោះជំពាក់បំណុលគេពាសវាលផង ចាំតែគេចមុខម្ចាស់បំណុលដែលតាមទារប្រាក់យ៉ាងអាម៉ាស់បំផុត។ លោកធ្លាក់ទឹកចិត្តរហូតដល់គិតបាញ់ក្បាលខ្លួនឯងឲ្យស្លាប់ផុតមុខផុតមាត់គេឯងទៅ។

លោក ស៊ុំប៊ូន ឲ្យដឹងដូច្នេះ ៖ *"ខ្ញុំសោកស្តាយខ្លាំងណាស់ ដើរទៅក្នុងចម្ការទឹកភ្នែកខ្ញុំហូររហាម។ ឈរមើលដើមទុរេនហើយស្ទើរតែដាច់ខ្យល់ស្លាប់ ព្រោះយើងដាំវាមកនឹងដៃ យើងស្រឡាញ់ដើមឈើណាស់ ឃើញវាងាប់នៅនឹងមុខ ធ្វើអ្វីលែងត្រូវតែឆ្លេឆ្លារកថ្នាំមកព្យាបាល តែក៏ជួយវាបានមិនប៉ុន្មានដើម ព្រោះគ្មានជំនាញនិងគ្មានទុន។ ដើរទៅជួបមិត្តភក្តិត្រូវគេចមុខព្រោះខ្មាសគេ។ ជួបម្ចាស់បំណុលក៏គេចមុខខ្មាសគេ។ ខ្ញុំទាញកាំភ្លើងចេញមកដើម្បីបញ្ចប់ជីវិតខ្លួនឯង លែងចង់រស់ទៀតហើយ ខ្មាសសត្វឆ្កែ"*។

តែលោក ស៊ុំប៊ូន មិនស្លាប់ ដោយសំណាងល្អយប់នោះចំថ្ងៃទី ៤ ធ្នូ កាលពី ១២ឆ្នាំមុន ស្តេចថៃ ព្រះចៅភូមិផុន អាឌុនដេត ទ្រង់បានថ្លែងសុន្ទរកថា ក្នុងឱកាសទិវាចម្រើនព្រះជន្មរបស់ព្រះអង្គ ដោយទ្រង់បានអធិប្បាយពីគុណសម្បត្តិនៃសេដ្ឋកិច្ចគ្រួសារ ដែលព្រះអង្គប្រទានឈ្មោះថាសេដ្ឋកិច្ចគ្រប់គ្រាន់។ គោលការណ៍សំខាន់នៃសេដ្ឋកិច្ចគ្រប់គ្រាន់នេះ គឺជាគោលការណ៍ស្រដៀងគ្នានឹងយុទ្ធសាស្ត្រលើកកម្ពស់កម្រិតជីវភាព ដោយការធ្វើកសិដ្ឋានគ្រួសារ ផ្សព្វផ្សាយដោយលោក លីកាំសាយ ក្នុងសៀវភៅប្រជុំបទពិសោធន៍ងាយយល់ស្រួលអនុវត្តរបស់លោកកាលពីឆ្នាំ ១៩៩៩ នោះដែរ។

ក្រោយពីបានស្តាប់ការណែនាំរបស់ព្រះមហាក្សត្រអំពីសេដ្ឋកិច្ចគ្រប់គ្រាន់ ដែលសង្កត់ធ្ងន់ទៅលើការដាំដំណាំចម្រុះ មិនដាំអ្វីតែមួយមុខដូចកសិករទូទៅនិយមធ្វើនោះមក លោក ស៊ុំប៊ូន ក៏ប្តេជ្ញាចិត្តអនុវត្តតាមលំនាំនេះយ៉ាងប្តូរផ្តាច់។ បច្ចុប្បន្នេះ លោក ស៊ុំប៊ូន បានសងប្រាក់គេអស់ហើយ ហើយនៅសល់ប្រាក់ជាច្រើន ក្លាយជាកុម្ពីដ៏សំខាន់មួយរូបនៅខេត្តឈុមផន គ្រួសាររបស់លោករស់នៅជួបជុំគ្នា ដោយមានចំណូលប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំឥតដាច់។

កាលពីឆ្នាំកន្លងទៅ លោក ស៊ុំប៊ូន មានចំណូលពីកសិដ្ឋានទំហំតែជាង ២ហិកតារនេះ សរុបជិត១លាន៤សែនបាត ស្មើនឹងប្រមាណ ១៤០លានរៀល។ តើលោក ស៊ុំប៊ូន អនុវត្តសេដ្ឋកិច្ចគ្រប់គ្រាន់ដោយវិធីណា?

ក្រោយបានយល់ដឹងអំពីនយោបាយសេដ្ឋកិច្ចគ្រប់គ្រាន់របស់ព្រះមហាក្សត្ររបស់ខ្លួនហើយ លោក សុំប៊ូន ក៏ងាកពីការដាំតែទុរេនមួយមុខក្នុងចម្ការមកជាដាំដំណាំចម្រុះ មានទាំងពីបន្លែបង្ការរហូតដល់ឈើហូបផ្លែ និងឈើព្រៃធំៗ ដូចជាឈើទាល ត្រាច ធ្នង់ គ្រញូង ជាដើម ព្រមទាំងចិញ្ចឹមត្រី ចិញ្ចឹមជ្រូកថែមទៀត លើផ្ទៃដីចម្ការដែលមានទំហំតែ ១៧រ៉ៃ ឬប្រមាណជា ២ហិកតារ ៧អារ នោះប៉ុណ្ណោះ។

តើលោក សុំប៊ូន ធ្វើវិធីណាទើបអាចប្តូរចម្ការទុរេនឲ្យក្លាយជាឧទ្យានរុក្ខជាតិ ដែលមានដំណាំដាំញឹកដូចព្រៃក្រាស់ដូច្នេះបាន? លោកមានប្រសាសន៍ថា លោកធ្លាប់ទៅទីក្រុង ហើយឃើញមានមនុស្សម្នាកកកុញ លោកសួរគេឯងថា តើគេរស់នៅបានដោយវិធីណាបើមនុស្សច្រើនម្លឹងៗ? គេប្រាប់ថា គេនៅ Condominium គឺផ្ទះច្រើនជាន់នៅបន្តុបលើគ្នា ធ្វើឲ្យកើតជាគំនិតដាំដំណាំជាផ្ទះខនដូ ៩ជាន់នេះឡើង។

លោក សុំប៊ូន ឲ្យដឹងដូច្នេះ ៖ *«បើនិយាយពីធ្វើចម្ការវិញ យើងមានដីតូចមួយទើបយើងមានគំនិតថា ប្រសិនបើយើងយកដើមឈើច្រើនប្រភេទមកដាំក្នុងចម្ការនេះ ដើម្បីឲ្យយើងរស់នៅបាន មានគ្រប់គ្រាន់សម្រាប់បរិភោគ មានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ បើដាំតែមួយមុខមិនគ្រាន់ទេ តែយើងត្រូវមើលថា តើដើមអីអាចដាំជាមួយដើមអីបាន? ឧទាហរណ៍ក្នុងទឹក យើងជីកស្រះដើម្បីយកទឹកទៅស្រោចទុរេន កាលបើជីកស្រះហើយយើងមិនយកតែទឹកប៉ុណ្ណោះទេ ត្រូវសួរថាតើអាចចិញ្ចឹមត្រីបានទេ? ដូច្នេះយើងចិញ្ចឹមត្រី ហើយដាំផ្កាឈូកទុកថ្វាយព្រះមហាក្សត្រិយានីផង។ នេះគឺជាខនដូ (condo) ជាន់ទីមួយ»*។

នៅជាន់ទីមួយ ឬក្នុងស្រះទឹក លោក សុំប៊ូន ចិញ្ចឹមត្រីត្រសក់ ត្រីរមាស និងត្រីទីឡាព្យ៉ាក្រហម។ ជាន់ទី ២ លោក សុំប៊ូន ដាំដំណាំដែលនៅក្រោមដី គឺប្រភេទមើមដំឡូង មានដំឡូងក្រអូប ដំឡូងជ្រូកជាដើម ៖ *«នេះជាដំណាំក្រោមដីប្រភេទមើម ដែលខ្ញុំដាំនៅពាសពេញចម្ការ។ អ្នកខ្លះនឹកស្មានថាជាដុំថ្ម តែដោយពិតវាគឺជាមើមដំឡូង»*។

ក្រៅពីនេះក៏មានខ្ទាយ រំដេង និងខ្ញី នៅជាន់ទី២ នេះផងដែរ។ លោក សុំប៊ូន ប្រាប់ឲ្យដឹងថា គ្រាន់តែខ្ទាយនិងរំដេង គាត់លក់មួយសប្តាហ៍ៗបានចំណូលមិនតិចជាង ២.០០០បាតឡើយ។ នៅក្នុងចម្ការរបស់លោក នៅគ្រប់ចង្អោមដីសុទ្ធតែមានភោគផលជីកយកមកដូរជាប្រាក់បានទាំងអស់។

នៅជាន់ទី៣ លោក សុំប៊ូន ដាំរុក្ខជាតិឱសថ ត្រួយរយោងសម្រាប់ស្ល ឬធ្វើជារបោយ ព្រមទាំងម្ទេស និងស្លឹកគ្រៃ។ នៅជាន់ទី៤ លោកដាំក្រូចជូរ ដែលចិនហៅថាក្រូចមាស លើផ្ទៃដី ៩រ៉ៃ ឬប្រមាណ១.០០០ ដើម ដែលផ្តល់ចំណូលសរុប ២.០០០បាតក្នុងមួយថ្ងៃ ៖ *«ក្រូចមាសនេះ កាលពីឆ្នាំទៅយើងមិនបានបេះលក់រាល់ថ្ងៃទេ ថ្ងៃខ្លះបេះបន្តិចបន្តួច ថ្ងៃខ្លះបេះច្រើន ទូទាត់ទៅចំណូលបានមួយថ្ងៃប្រមាណ ២.០០០ បាត»*។

ជាន់ទី៥ លោកដាំចេកដែលផ្ដល់ចំណូល ៥ ទៅ ៦ពាន់បាតក្នុងមួយសប្ដាហ៍ គឺរៀងរាល់សប្ដាហ៍លោកកាប់ចេកលក់ម្ដង។ នៅពេលមានគេប្រាប់លោកថា ការដាំដំណាំច្រើនមុខញឹកស្ពេកពេកមិនល្អឡើយ ព្រោះវានឹងដណ្ដើមអាហារគ្នា លោក សុំប៊ូន មានប្រសាសន៍ថា ៖ *«មិនពិតទេ! មើលចុះវាជាជីឲ្យគ្នាទៅវិញទៅមកទេតើ! គឺវាជួយជ្រោមជ្រែងគ្នាទៅវិញទៅមក»*។

ជាន់ទី៦ គឺជាទុរេននៅក្នុងចម្ការទាំងអស់ ដែលលោក សុំប៊ូន ដាំបានជាង ៧០០ដើម លាយឡំពូជគ្នា តែភាគច្រើនគឺជាពូជម៉នថង។ អ្វីដែលគួរឲ្យកត់សម្គាល់ គឺជាន់ទី៧ ដែលលោកដាំម្រេចដោយបំពាក់ទៅលើដើមទុរេន គឺយកដើមទុរេនធ្វើជាជន្លង់ ៖ *«នៅលើដើមទុរេននីមួយៗ ពីដើមយើងដាំម្រេចជាដំណាំអនុផល តែឥឡូវនេះម្រេចក្នុងចម្ការរបស់ខ្ញុំបានក្លាយជាដំណាំគោលទៅហើយ ព្រោះថាចំណូលកាលពីឆ្នាំទៅបានដល់ទៅជាង ៣០ម៉ឺនបាត គឺជិតស្មើនឹងចំណូលពីទុរេនតែម្ដង»*។

លោក សុំប៊ូន មានប្រសាសន៍ថា នៅពេលលោកផ្ដើមដាំម្រេចឲ្យតោងដើមទុរេន មានតែមនុស្សគេរិះគន់លោក រួមទាំងឪពុករបស់លោកផង។ ម្នាក់ៗ ថាប្រើដើមទុរេនជំនួសជន្លង់ម្រេច មិនដែលមាននរណាគេធ្វើទេ ៖ *«លោកឪពុកខ្ញុំគាត់ថែមទាំងជេរផង ថាកុំដាំអ៊ីចឹង ប្រយ័ត្នម្រេចងាប់អស់។ ខ្ញុំក៏សាកល្បងដាំមួយដើមសិន ព្រោះមិនដឹងជាយកទៅដាំត្រង់ណា ខណៈដែលមានម្រេចពូជល្អឲ្យដាំទៅហើយនោះនេះម្យ៉ាង ហើយម្យ៉ាងទៀតជន្លង់នោះក៏ថ្លៃណាស់ផង។ ជន្លង់មួយដើមថ្លៃរាប់រយបាត។ អ៊ីចឹងខ្ញុំក៏ដាំសាកមើលមួយដើមសិន។ ក្នុងរយៈពេល ៤ឆ្នាំ គឺនៅឆ្នាំទី៤ ខ្ញុំប្រមូលផលបានដល់ទៅជាង ៨០គីឡូក្រាម ឃើញថាបានផលល្អទើបដាំពេញមួយចម្ការតែម្ដងទៅ»*។

ចំពោះដំណាំម្រេច លោក សុំប៊ូន ប្រមូលផលរៀងរាល់ថ្ងៃជាម្រេចស្រស់ ហើយនៅចុងឆ្នាំលោកប្រមូលផលម្រេចចាស់យកទៅហាល លក់បានមួយសាទៀត។ ក្នុងមួយថ្ងៃៗ គ្រាន់តែបេះម្រេចស្រស់ទៅលក់នៅទីផ្សារក៏មានចំណូលពី ១ពាន់ ទៅ ២ពាន់បាតប្រាក់ថៃដែរ ហើយនៅចុងឆ្នាំលក់ម្រេចស្ងួតបានចំណូល ២០-៣០ម៉ឺនបាតថែមទៀត។ ដូច្នេះហើយទើបនៅក្នុងចម្ការរបស់លោកសុំប៊ូន គេឃើញម្រេចដុះតោងដើមទុរេន ទាំងជាង ៧០០ដើមនោះឡើងទ្រុប។

និយាយពីដំណាំប្រភេទវល្លិ៍ដេង ខ្ទាយ ខ្ញី និងរមៀត លោក សុំប៊ូន បានប្រាប់ហើយថា លោកដាំនៅគ្រប់កន្លែងដែលដីនៅទំនេរ ហើយលោកបានឲ្យដឹងថា លោកជីកលក់ឲ្យរោងចក្រផលិតម្សៅមើមរុក្ខជាតិឱសថទាំងនេះ មួយសប្ដាហ៍ម្ដង រៀងរាល់សប្ដាហ៍ គឺមានកុងត្រាផ្ដល់ឲ្យគេទទួលទិញឥតដាច់។

សួរថាបើតម្លៃលើទីផ្សារធ្លាក់ចុះ តើមានបញ្ហាអ្វីនឹងផលិតផលទាំងនេះដែរទេ? លោក សុំប៊ូន ស៊ីស៊ុបាត់មានប្រសាសន៍ថា ៖ *"ខ្ទាយបើមិនជីកវាក៏មិនបង្កជារឿងឲ្យក្ដៅក្រហាយអ្វីដែរ។ ឆ្នាំនេះបានប៉ុណ្ណេះ គឺក្នុងមួយគុម្ពជីកបានប្រមាណ ១គីឡូក្រាម។ បើមិនជីកវា ទុកដល់ឆ្នាំក្រោយ មិនមែនបាន ២គីឡូទេ គឺបាន*

*ដល់ទៅ ៣ ឬ ៤គីឡូឯណោះ។ វានឹងរីកធំធាត់ទ្វេគុណ ២ ទៅ ៣ដង ហើយបើទុក ៣ឆ្នាំ មួយគុម្ពដែលនេះនឹងផ្តល់ផលដល់ទៅ ១០គីឡូក្រាម"*។

ក្នុងចម្ការដែលលោក សុំប៊ូន សន្មតថា ជាផ្ទះខនដូ ៩ជាន់នេះ យើងបានឮហើយថាមានជាន់ទី១ ដែលជាស្រះទឹកសម្រាប់ស្រោចដំណាំផង ចិញ្ចឹមត្រីផង និងដាំឈូក ព្រលិត និងត្រកួនផង។ ជាន់ទី២ គឺពពួកដំឡូងនិងរុក្ខជាតិមើម ឬប្រទាលនានា ដូចជា រំដេង ខ្ញី ខ្ជាយ រមៀតជាដើម។ ទី៣ គឺបន្លែបង្ការ ស្លែខាត់ណា ម្ទេស ស្លឹកគ្រៃ ។ល។ ទី៤ គឺក្រូចចិន ហៅក្រូចមាស ដែលផ្តល់ចំណូល ១ថ្ងៃ ប្រមាណ ២.០០០បាត។ ទី៥ ដាំចេកកាប់លក់រាល់អាទិត្យ។ ទី៦ គឺទុរេនជាង ៧០០ដើម ដើមស្លា ជាង ១០០ដើម ឈើហូបផ្លែ ដូចជាឡងកង ៥០ដើម លាំងសាត ៥០ដើម មង្ឃុត ១០០ដើម និងក្រូចថ្លុង ក្រូចពោធិ៍សាត់ជាច្រើនទៀត។

នៅជាន់ទី៧ លោក សុំប៊ូន ដាំម្រេចពូជល្អ ដោយប្រើដើមឈើធំៗ មានទុរេន ឈើខ្លឹមជាជន្លង់។ បានសេចក្តីថា ក្នុងចម្ការនេះ លោក សុំប៊ុន មិនដាំត្រឹមតែបន្លែបង្ការ ទុរេន និងឈើហូបផ្លែ តែប៉ុណ្ណោះទេ លោកដាំរហូតដល់ឈើខ្លឹមថែមទៀត ដែលលោកចាត់ថាជាជាន់ទី៨ នៃចម្ការផ្ទះខនដូ ៩ជាន់នេះ។ ឈើខ្លឹមទាំងនេះ គឺជាវិភាគទានរបស់កសិករថៃរូបនេះចំពោះការការពារបរិស្ថាន និងទប់ស្កាត់កំណើនកម្តៅផែនដី ដែលគេហៅថា Global warming ធ្វើឲ្យបានមកនូវម្លប់ និងភាពត្រជាក់ត្រឈឹងត្រឈៃ។ ក្រៅពីនេះដើមឈើធំៗ ដូចជាបេង ស្រឡៅ ធ្នឹក ធ្នង់ គគីរ ដែលលោកដាំពង្រាយក្នុងចម្ការ គឺជាប្រាក់សន្សំទុកក្នុងធនាគាររុក្ខជាតិសម្រាប់អនាគតទៀតផង។

លោក សុំប៊ូន បានដាំឈើខ្លឹមទាំងអស់ជាង ១.៣០០ដើម ដែលពូជបានពីរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម ៖ *"ដាំដើមឈើនិងដាំទុរេនខុសគ្នាត្រង់ដែលថា ដាំទុរេនយើងត្រូវស្រោចទឹកវា តែដាំឈើខ្លឹមយើងពឹងឲ្យទេវតាចិញ្ចឹម។ ដាំហើយយើងមិនបាច់ដាក់ជី មិនបាច់ស្រោចទឹក មិនបាច់ដាក់អ្វីវាទាំងអស់ តែវាធំលូតលាស់រៀងរាល់ថ្ងៃ។ យោងតាមស្ថិតិ ក្រោយទូទាត់លាត់សើយហើយ ឃើញថា វាធំមួយថ្ងៃ ៣បាត។ ថ្ងៃណាមួយ បើយើងហត់នឿយ យើងក៏អាចទៅវិស្សមកាលកំសាន្តនៅទីណាក៏បាន ដើមឈើវារីកលូតលាស់រាល់ថ្ងៃមិនបាច់ព្រួយបារម្ភពីវាឡើយ។ យើងដាំវាធ្វើជាជន្លង់ម្រេចក៏បាន។ រឿងកាប់វាយើងមិនបាច់គិតទេ គឺទុកវាជាមរតកដល់កូនចៅ។ ទុកឲ្យកូនចៅគេកាប់វាទៅចុះ យើងមិនបាច់កាប់វាទេ។ តែបើ ២០-៣០ឆ្នាំទៀត យើងមិនទាន់ស្លាប់ ថ្ងៃណាមួយចង់ទៅលេងប្រទេសជប៉ុន ឬទស្សនាកំសាន្តជុំវិញពិភពលោក យើងអាចកាប់តែ ២ដើម លក់បានប្រាក់រាប់ម៉ឺនសម្រាប់ជាវង្វាន់ដល់ជីវិតយើង។ មានជាង ១ពាន់ដើម កាប់តែ ២ដើម វាមិនអស់ទេ បើកាប់រួចដាំជំនួសវិញភ្លាមនោះ"*។

មកដល់ជាន់ទី៩ ដែលជាជាន់កំពូលនៃចម្ការបែបផ្ទះខនដូ របស់លោក សុំប៊ូន គេឃើញមានដើមឈើលូតស្រឡូនជាច្រើនដើម។

លោក ស៊ុំប៊ូន អធិប្បាយដូច្នេះ ៖ *"ទាំងអស់នេះគឺដើមឈើទាល ជាជាន់ទី៩។ យើងទើបនឹងដាំបានមួយឆ្នាំ។ ឈើទាល គឺជាស្តេចនៃដើមឈើ មានកម្ពស់ប្រមាណ ៩០ម៉ែត្រ។ ក្នុងជីវិតរបស់ខ្ញុំ ហ្លួងគឺជារបស់ខ្ពស់បំផុតសម្រាប់ជីវិតខ្ញុំ។ ខ្ញុំស្រឡាញ់ព្រះករុណាព្រះមហាក្សត្រ ហើយខ្ញុំចង់ធ្វើអ្វីម្យ៉ាងដើម្បីព្រះអង្គ។ ដូច្នេះក្នុងចម្ការនេះ ខ្ញុំមានគំនិតថា ត្រូវតែដាំដើមឈើទាលថ្វាយដល់ព្រះករុណា។ដូច្នេះហើយទើបជាន់នេះ ហៅថាជាន់ទី៩ ដែលជាជាន់កំពូល មានតម្លៃខាងផ្លូវចិត្តសម្រាប់ខ្ញុំជាទីបំផុត"*។

លោក ស៊ុំប៊ូន មានប្រសាសន៍ថា ជីវិតមនុស្សយើងមានន័យ ឬអត់ មិនមែននៅនឹងចំនួនប្រាក់ក្នុងធនាគារនោះឡើយ តែនៅនឹងការពេញចិត្តនឹងអ្វីដែលខ្លួនមាន ដែលខ្លួនបានមកដោយក្តីសុចរិត និងឧស្សាហ៍ព្យាយាម។ លោកធ្វើចម្ការប្រភេទដំណាំចម្រុះនេះ ដោយវិរិយភាពជាច្រើនឆ្នាំ រហូតដល់សងបំណុលគេអស់ក្លាយខ្លួនជាក្តុម្ពី មានមុខមានមាត់ មានប្រាក់ចំណូលឥតដាច់រាល់ថ្ងៃ រាល់អាទិត្យ រាល់ខែ និងរាល់ឆ្នាំ។

លោក ស៊ុំប៊ូន មានប្រសាសន៍ដូច្នេះ ៖ *"ឧត្តមគតិរបស់ខ្ញុំ គឺធ្វើចម្ការដើម្បីស៊ីចុក ស៊ីចុកឆ្អែតហើយខ្ញុំចែកចាយដល់អ្នកដទៃ រួចហើយយកទៅដោះដូរមុននឹងលក់ចេញជាទំនិញ"*។